ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៤៧០ ឧសថ.បថ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៤

# ប្រកាស

## ស្តីពីការបង្កើតស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- តាមសំណូមពរចាំបាច់ និងស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន

## សំរេច

**ប្រការ១:** បង្កើតស្តង់ដាបច្ចេកទេសអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាសំរាប់អនុវត្តក្នុងផ្នែកសំខាន់ៗចំនួន ០៥ដូចតទៅ:

១- ស្ថានីយ៍ផលិតថាមពលអគ្គិសនីដើរដោយប្រេងឥន្ធនៈ និងចំហាយ

២- ស្ថានីយ៍វារីអគ្គិសនី

៣- ប្រព័ន្ធខ្សែបណ្តាញបញ្ជូនអគ្គិសនី និងប្រព័ន្ធខ្សែបណ្តាញចែកចាយអគ្គិសនី

៤- ប្រព័ន្ធថាមពលកកើតឡើងវិញ និង

៥- ប្រព័ន្ធខ្សែបណ្តាញអគ្គិសនីតាមគេហដ្ឋាន និងអាគារទូទៅ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ :(៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣. ៤២៨២៦៣
45 Preah Norodom Boulevard , Khan Daun Penh, Phnom Penh , Phone : 855. 23 . 211141 Fax : 855 23 428263

**ប្រការ២:** ប្រកាសឱ្យប្រើល័ក្ខខ័ណ្ឌទូទៅនៃស្តង់ដាបច្ចេកទេសអគ្គិសនីដែលមានខ្លឹមសារទាំងស្រុងភ្ជាប់ជាមួយប្រកាសនេះ ។

**ប្រការ៣:** ល័ក្ខខ័ណ្ឌលំអិតតាមផ្នែកនីមួយៗ នឹងត្រូវរៀបចំ និងប្រកាសឱ្យប្រើប្រាស់ជាបន្តបន្ទាប់តាមអាទិភាព ។

**ប្រការ៤:** សេវាករអាជីវកម្មអគ្គិសនី និងអ្នកប្រើប្រាស់អគ្គិសនីទាំងអស់ ត្រូវអនុវត្តស្តង់ដានេះជាដាច់ខាត ។

**ប្រការ៥:** ចំពោះអ្នកធ្វើសេវាកម្មអគ្គិសនី អនុញ្ញាតឱ្យបន្តប្រើប្រាស់ប្រព័ន្ធអគ្គិសនីកំពុងដំណើរការបច្ចុប្បន្នរយៈពេលចំនួនពីរឆ្នាំទៀត ដោយគិតចាប់ពីថ្ងៃចេញប្រកាសនេះ ដើម្បីផ្លាស់ប្តូរកែលំអឱ្យស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនី ។ ការពន្យាពេលលើសពីនេះ អាស្រ័យដោយការសំរេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ ចំពោះប្រព័ន្ធខ្សែបណ្តាញអគ្គិសនីតាមគេហដ្ឋាន និងអាគារទូទៅដែលកំពុងប្រើប្រាស់ អនុញ្ញាតឱ្យប្រើប្រាស់បន្ត លើកលែងតែប្រព័ន្ធដែលគ្មានសុវត្ថិភាព។ នៅពេលកែលំអ ឬផ្លាស់ប្តូរថ្មីត្រូវអនុវត្តតាមស្តង់ដានេះ ។

**ប្រការ៦:** ប្រកាស ឬសេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៧:** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស៊ុយ_សែម**